ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៩ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការគ្រប់គ្រងមណ្ឌលថែទាំកុមារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសុំកូនអន្តរប្រទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- យោងតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការគ្រប់គ្រងមណ្ឌលថែទាំកុមារនិងការការពារឧត្តមប្រយោជន៍កុមារ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅគ្រប់គ្រងមណ្ឌលថែទាំកុមារ ដែលផ្តល់នូវការថែទាំ ស្នាក់នៅ និងផ្តល់នូវតម្រូវការជាមូលដ្ឋានឲ្យកុមាររស់នៅជាក្រុមដល់កុមារដែលគ្មានឪពុកម្តាយ ឬគ្មានឪពុក ឬគ្មានម្តាយ ឬកុមារដែលត្រូវគេបោះបង់ចោល ឬក៏កុមារដែលឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលពុំមានលទ្ធភាពផ្តល់ការថែទាំគ្រប់គ្រាន់។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះមណ្ឌលថែទាំកុមារទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៤ .-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងមណ្ឌលថែទាំកុមារ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាត្រួតពិនិត្យនិងវាយតម្លៃអំពីសមត្ថភាពនិងលទ្ធភាពដោយផ្អែកលើសភាពការណ៍ជាក់ស្តែង ដើម្បីធ្វើប្រតិភូកម្មនិងផ្ទេរមុខងារគ្រប់គ្រងមណ្ឌលថែទាំកុមារដែលអាចផ្ទេរបាន ជាដំណាក់កាលឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៥ .-**

ក្នុងការបង្កើត ដំណើរការអនុវត្ត ការសម្របសម្រួល ការត្រួតពិនិត្យ និងការវាយតម្លៃមណ្ឌលថែទាំកុមារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបង្គាប់នាយកដ្ឋានជំនាញឲ្យបំពេញភារកិច្ចដូចតទៅ៖

- ទទួលពាក្យស្នើសុំបើកមណ្ឌលថែទាំកុមារ
- ចុះធ្វើការប៉ាន់ប្រមាណលក្ខណសម្បត្តិរបស់រូបវន្តបុគ្គលឬនីតិបុគ្គល ស្នើសុំធ្វើរបាយការណ៍ និងលើកយោបល់ជំនាញជូនថ្នាក់ដឹកនាំក្រសួងដើម្បីពិនិត្យនិងសម្រេច/.

- ចុះកំណត់អត្តសញ្ញាណមណ្ឌលថែទាំកុមារទាំងអស់
- ចុះធ្វើអធិការកិច្ចលើការអនុវត្តបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារនៅក្នុងមណ្ឌល
- ផ្តល់ការណែនាំនិងកែលម្អផ្នែកបច្ចេកទេសដល់មណ្ឌលថែទាំកុមារដែលមិនអនុវត្តស្របតាមបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារ
- បង្កើតសេវាតាមដាននិងគាំទ្រសម្រាប់កុមារ និងគ្រួសារក្រោយពេលបង្រួបបង្រួម
- កំណត់ផែនទីមណ្ឌលថែទាំកុមារទាំងអស់ និងបង្កើតកម្មវិធីមូលដ្ឋានទិន្នន័យសម្រាប់គ្រប់គ្រងកុមារ
- ចេញបញ្ជាបិទមណ្ឌលថែទាំកុមារ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

## ជំពូកទី៣
## ការអនុញ្ញាតឲ្យដំណើរការមណ្ឌលថែទាំកុមារ

**មាត្រា៦ .-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលបង្កើតមណ្ឌលថែទាំកុមារ ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា៧ .-**

លក្ខណវិនិច្ឆ័យដែលអនុញ្ញាតឲ្យបង្កើតមណ្ឌលថែទាំកុមារ ត្រូវមានប្រភពធនធានថវិកា ធនធានមនុស្ស សមត្ថភាពអ្នកថែទាំ ក្រមសីលធម៌ និងមានទីតាំងភូមិសាស្ត្រនៅតំបន់គោលដៅដែលចាំបាច់។

**មាត្រា៨ .-**

លក្ខខណ្ឌនិងទម្រង់បែបបទនៃការដាក់ពាក្យស្នើសុំការអនុញ្ញាតបង្កើតមណ្ឌលថែទាំកុមារ និងការជ្រើសរើសបុគ្គលិកថែទាំកុមារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ជំពូកទី៤
## ភារកិច្ចរបស់មណ្ឌលថែទាំកុមារ

**មាត្រា៩ .-**

រាល់មណ្ឌលថែទាំកុមារទាំងអស់ត្រូវបំពេញនូវភារកិច្ចដូចខាងក្រោម៖

- កសាងសំណុំឯកសារឲ្យបានច្បាស់លាស់សម្រាប់កុមារម្នាក់ៗ ចាប់ពីពេលដែលកុមារចូលមករស់នៅក្នុងមណ្ឌលថែទាំកុមារ

- គ្រប់គ្រងរក្សាសំណុំឯកសារកុមារម្នាក់ៗតាមប្រព័ន្ធទិន្នន័យច្បាស់លាស់ និងធ្វើរបាយការណ៍ជាប្រចាំ
- រៀបចំផែនការសម្រាប់បង្រួបបង្រួមគ្រួសារ និងធ្វើសមាហរណកម្មកុមារទៅកាន់គ្រួសារ និងសហគមន៍វិញ
- មានវិធានការ បទបញ្ជា និងនីតិវិធី ដើម្បីទប់ស្កាត់និងដោះស្រាយករណីរំលោភបំពានលើកុមារនៅក្នុងមណ្ឌល ដោយកំណត់ច្បាស់លាស់អំពីនីតិវិធីបណ្ដឹង ការរាយការណ៍ ការស៊ើបអង្កេត ព្រមទាំងនីតិវិធីក្នុងការការពារនិងគាំទ្រដល់កុមារ ហើយត្រូវផ្សព្វផ្សាយដល់បុគ្គលិកនិងកុមារបានដឹង
- រាយការណ៍អំពីករណីរំលោភបំពានលើកុមារនៅក្នុងមណ្ឌលថែទាំកុមារជូនក្រសួង មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ក្នុងរយៈពេល ៤៨ម៉ោងយ៉ាងយូរ
- សហការល្អជាមួយអាជ្ញាធរដែនដីក្នុងកិច្ចការថែទាំកុមារ
- ត្រូវគោរពនូវលក្ខខណ្ឌផ្សេងទៀតដូចមានចែងក្នុងមាត្រា១០នៃអនុក្រឹត្យនេះ។

**មាត្រា១០.-**

មណ្ឌលថែទាំកុមារត្រូវគោរពនូវលក្ខខណ្ឌនៃការគ្រប់គ្រងមណ្ឌលនិងការថែទាំកុមារដែលរស់នៅក្នុងមណ្ឌលស្របតាមលិខិតបទដ្ឋានគតិយុត្តជាតិ អន្តរជាតិ និងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការថែទាំជំនួសចំពោះកុមារ។

## ជំពូកទី៥
## ប្រភេទកុមារដែលអាចអនុញ្ញាតឲ្យរស់នៅឬ បញ្ឈប់ឲ្យរស់នៅក្នុងមណ្ឌលថែទាំកុមារ

**មាត្រា១១.-**

កុមារដែលអាចអនុញ្ញាតឲ្យរស់នៅក្នុងមណ្ឌលថែទាំកុមារបាន ជាប្រភេទកុមារដែលមានលក្ខណៈដូចខាងក្រោម៖

- កុមារដែលគ្មានឪពុកម្ដាយ ឬអាណាព្យាបាលដែលខ្លួនអាចរស់នៅជាមួយបាន
- កុមារបែកចេញពីគ្រួសារ តាមរយៈការបោះបង់កុមារចោល ឪពុកម្ដាយឬអាណាព្យាបាលជាប់ពន្ធនាគារ ការជួញដូរ ឬចំណាកស្រុក
- កុមារបែកចេញពីគ្រួសារបណ្ដាលមកពីស្ថានភាពគំរាមកំហែង
- កុមារទទួលរងការប្រព្រឹត្តអំពើហិង្សា ឬការគំរាមបង្កអំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពានលើរាងកាយ ឬផ្លូវភេទ ឬការកេងប្រវ័ញ្ចគ្រប់រូបភាព ដូចជាការលក់ទិញ ឬជួលកុមារជាដើម។

- កុមារដែលឪពុកម្តាយ ឬអាណាព្យាបាលរបស់ខ្លួនពុំមានលទ្ធភាពបំពេញកាតព្វកិច្ចបីបាច់ថែរក្សាដោយសារលំបាកបំផុត ខ្វះខាតម្រូវការចាំបាច់និងសេវាមូលដ្ឋាន ទីជម្រក ចំណីអាហារ សម្លៀកបំពាក់ ការអប់រំ និងការថែទាំសុខភាព
- កុមារដែលអ្នកថែទាំកុមារមានជំងឺរ៉ាំរ៉ៃ ឬមានពិការភាព ដែលមិនអាចផ្តល់ការថែទាំកុមារបានសមស្រប
- កុមារដែលគ្រួសារញៀនគ្រឿងស្រវឹង លេងល្បែងស៊ីសង ប្រើប្រាស់សារធាតុញៀនផ្សេងៗដែលមិនអាចផ្តល់ការថែទាំសមស្របដល់កុមារ។

ការអនុញ្ញាតឲ្យកុមាររស់នៅក្នុងមណ្ឌលថែទាំកុមារជាជម្រើសចុងក្រោយ និងបណ្តោះអាសន្ន ហើយអាចដំណើរការទៅបានបន្ទាប់ពីអស់លទ្ធភាពក្នុងការស្វែងរកឪពុកម្តាយ ឬឪពុក ឬម្តាយ សាច់ញាតិឬអាណាព្យាបាល ឬឪពុកឬម្តាយចិញ្ចឹមបាន។

**មាត្រា១២ .-**

កុមារដែលកំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារ អាចត្រូវបញ្ឈប់ឲ្យរស់នៅក្នុងមណ្ឌលថែទាំកុមារបាន ដោយធ្វើសមាហរណកម្មកុមារនោះឲ្យទៅរស់នៅក្នុងសហគមន៍វិញ ជាប្រភេទកុមារដែលមានលក្ខណៈដូចខាងក្រោម៖

- កុមារដែលឪពុកម្តាយ ឬឪពុកឬម្តាយឬអាណាព្យាបាលដែលអាចមានលទ្ធភាពទទួលយកកុមារត្រឡប់ទៅរស់នៅជាមួយគ្រួសារសាច់ញាតិវិញបាន
- កុមារដែលមានឪពុកម្តាយចិញ្ចឹមនៅក្នុងប្រទេសឬនៅក្រៅប្រទេស
- យុវជនដែលលក្ខណសម្បត្តិគ្រប់គ្រាន់អាចចេញទៅរស់នៅក្នុងសហគមន៍ដោយខ្លួនឯងបាន ដូចជាយុវជនមានការងារធ្វើ មានមុខរបរ មានប្រាក់ខែ ទោះបីនៅលីវឬបានរៀបអាពាហ៍ពិពាហ៍រួចហើយក្តី។

## ជំពូកទី៦
## ការដោះស្រាយវិវាទ

**មាត្រា១៣.-**

ក្នុងករណីទទួលបានព័ត៌មានឬរបាយការណ៍ស្តីពីបាតុភាពមិនប្រក្រតីកើតមានតាមមណ្ឌលថែទាំកុមារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវធ្វើអធិការកិច្ចជាបន្ទាន់ ក្នុងរយៈពេលមិនលើសពី៤៨ម៉ោង ដើម្បីដោះស្រាយបាតុភាពទាំងនោះ។

ក្នុងករណីមានបណ្តឹងឬរបាយការណ៍ស្តីពីការរំលោភបំពាន អំពើហិង្សា ឬការមិនយកចិត្តទុកដាក់លើកុមារដែលកំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយជូន

មហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងសុខាភិបាល និងតំណាងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបង្កើតគណៈកម្មការចម្រុះក្នុងការចាត់វិធានការតាមផ្លូវច្បាប់។

**មាត្រា១៤ .-**

ករណីមានការសង្ស័យអំពីការរំលោភបំពានលើកុមារដោយអ្នកគ្រប់គ្រងឬបុគ្គលិកក្នុងមណ្ឌល និងមានការស៊ើបអង្កេតពីសមត្ថកិច្ចក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវព្យួរការងារជនបង្កជាបណ្តោះអាសន្ន មិនឲ្យពាក់ព័ន្ធជាមួយកុមារដោយផ្ទាល់។ រាល់ការដកហូតកុមារចេញពីការថែទាំ ត្រូវសម្រេចធ្វើឡើងដោយតម្កល់ឧត្តមប្រយោជន៍របស់កុមារ។

## ជំពូកទី៧
## ទណ្ឌកម្ម

**មាត្រា១៥ .-**

មណ្ឌលថែទាំកុមារដែលមិនអនុវត្តតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មដូចខាងក្រោម៖

- ព្រមានជាលាយលក្ខណ៍អក្សរ
- ផ្អាកសកម្មភាពជាបណ្តោះអាសន្ន
- ដកហូតលិខិតអនុញ្ញាតជាស្ថាពរ។

ទណ្ឌកម្មខាងលើនេះមិនរារាំងដល់ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

**មាត្រា១៦.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលបង្កើតឬដំណើរការគ្រប់គ្រងមណ្ឌលថែទាំកុមារដែលគ្មានការអនុញ្ញាតពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាជាមុន ត្រូវចាត់ទុកជាមណ្ឌលលួចលាក់និងត្រូវទទួលទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា១៧ .-**

គ្រប់មណ្ឌលថែទាំកុមារ ដែលបានដំណើរការមុនអនុក្រឹត្យនេះចូលជាធរមាន ហើយមិនទាន់មានការអនុញ្ញាតពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវមកសុំការអនុញ្ញាតក្នុងរយៈពេលយ៉ាងយូរ៦(ប្រាំមួយ)ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។

**មាត្រា១៨ .-**

ក្រោយអនុក្រឹត្យនេះចូលជាធរមាន ប្រកាសរបស់ក្រសួងដែលពាក់ព័ន្ធនឹងការថែទាំជំនួសចំពោះកុមារ ត្រូវបន្តអនុវត្តរហូតមានប្រកាសថ្មីមកជំនួស។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា១៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០១៥

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**វង សូត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ